# ការតស៊ូរបស់សហគមន៍ខេត្តព្រះវិហារ ជាមួយក្រុមហ៊ុនស្ករអំពៅចិន



ទិដ្ឋភាពនៃតំបន់សម្បទានសេដ្ឋកិច្ចដែលក្រុមហ៊ុនកំពុងតែកែប្រែពីវាលស្រែ ព្រៃឈើ និងអូរ ប្រឡាយឲ្យក្លាយទៅជាមហាសមុទ្រចំការអំពៅ។ (រូបថត : សហគមន៍ប្រមេរ)

**បណ្តាញសហគមន៍ ដើម្បីសកម្មភាព (ស៊ី.អិន.អេ) អង្គការពន្លកខ្មែរ (ភី.ខេ.អេក)**

**អង្គការគ្រេន (GRAIN) សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (ស៊ីយ៉ា)**

**សម្ព័ន្ធជនជាតិដើមភាគតិចអាស៊ី (អេ.អាយ.ភី.ភី)**

ប្រជាពលរដ្ឋរាប់ម៉ឺននាក់បានរងផលប៉ះពាល់ពីការរំលោភដីធ្លីនៅខេត្តព្រះវិហារនៃប្រទេសកម្ពុជា ដែលបានកើតឡើងតាំងពីឆ្នាំ២០១១ ក្នុងនោះមានក្រុមហ៊ុនចិនចំនួន ៥ ត្រូវបានរដ្ឋាភិបាលកម្ពុជាប្រគល់ដីសម្បទានសេដ្ឋកិច្ចដែលគ្របដណ្តប់លើផ្ទៃដីជាង៩០,០០០ហិកតា។ ប្រជាពលរដ្ឋបានបាត់បង់លទ្ធភាពផលិតស្បៀង និង ជីវភាពរបស់ខ្លួន ដោយសារក្រុមហ៊ុនទាំង ៥ នេះបានយកដីស្រែចំការ ព្រៃឈើ តំបន់វាល និងអូរ កែប្រែទៅជាចំការអំពៅ។ ដោយដីសម្បទាននេះបានហ៊ុំព័ទ្ធយឿនប្រាសាទបុរាណយ៉ាងតិច ១៩ កន្លែង ប្រទេសកម្ពុជាក៏បានបាត់បង់មួយផ្នែកនៃមរតកវប្បធម៌របស់ខ្លួនផងដែរ។ សហគមន៍ដែលរងផលប៉ះពាល់បានធ្វើការតតាំងយ៉ាងខ្លាំងចំពោះការបំផ្លាញជីវភាព និង វប្បធម៌របស់គាត់ ហើយពួកគាត់បានទាមទារការលប់សម្បទាន និងប្រគល់ដីត្រឡប់ទៅឲ្យសហគមន៍ តាំងពីក្រុមហ៊ុនមកដល់ដំបូងម្លេះ។ រហូតដល់សព្វថ្ងៃ ទោះបីពួកគាត់អាចបន្ថយល្បឿននៃការពង្រីកចំការអំពៅ មិនអាចបញ្ឈប់ការរំលោភពីក្រុមហ៊ុនបាន តែគាត់មិនទាន់បានបោះបង់ការទាមទារនៅឡើយ។ របាយការណ៍នេះបង្ហាញនូវអត្ថន័យនៃការរំលោភដីធ្លីនៅព្រះវិហារសម្រាប់សហគមន៍អស់រយៈពេល ៦ ឆ្នាំកន្លងមក គឺការរំលោភសិទ្ធិមនុស្ស ការបាត់បង់ជីវភាព និង ការបំផ្លាញវប្បធម៌ និង បរិស្ថាន។

ក្រុមហ៊ុនសរុបចំនួន ៥ ដែលគេជឿជាក់ថាជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនចិនតែមួយក្នុងកិច្ចសហការណ៍ជាមួយក្រុមហ៊ុនចិនមួយទៀត ទទួលបានសម្បទានដីសេដ្ឋកិច្ចដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ៣៦,០០០ ហិកតាក្នុងខេត្តព្រះវិហារ នៅភាគឧត្តរនៃប្រទេសកម្ពុជា[១]។ យោងតាមអនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាគឺជាដីដែលរដ្ឋាភិបាលជួលអោយក្រុមហ៊ុនឯកជនដើម្បីប្រើប្រាស់សម្រាប់កសិកម្ម ឬកសិឧស្សាហកម្ម។ ក្នុងចំណោមក្រុមហ៊ុនទាំង ៥ មានក្រុមហ៊ុនមួយ គឺរ៉ូយហ្វេង បានសាងសង់រោងចក្រផលិតស្ករសក្នុងដីសម្បទានរបស់ខ្លួន ដោយអះអាងថាបានចំណាយទុនអស់ចំនួន៣៦០ លានដុល្លារ ហើយថារោងចក្រនេះស្ថិតក្នុងចំណោមរោងចក្រស្ករសដែលធំជាងគេនៅអាស៊ី នៅដំណាក់កាលដំបូងរោងចក្រនេះមានលទ្ធភាពផលិតស្ករសបាន២,០០០ តោនក្នុងមួយថ្ងៃ[២]។

សម្បទានដីសេដ្ឋកិច្ចដំបូងនៅកម្ពុជាត្រូវបានផ្តល់តាំងពីឆ្នាំ១៩៩៥ ហើយដល់ឆ្នាំ២០១២ សម្បទានដីសេដ្ឋកិច្ចបានគ្របដណ្តប់លើផ្ទៃដីជាង ១១ ភាគរយនៃផ្ទៃដីទូទាំងប្រទេស ដោយមានសម្បទានរ៉ែគ្របដណ្តប់ផ្ទៃដីជិតស្មើគ្នាដែរ[៣]។ សម្បទានដីសេដ្ឋកិច្ចត្រូវផ្តល់លើដីរបស់រដ្ឋដែលមិនបំរើប្រយោជន៍សាធារណៈ តែជាក់ស្តែង សម្បទានដីសេដ្ឋកិច្ចជាច្រើនបានគ្របដណ្តប់ដីស្រែ ដីចំការ និងដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ហើយតែងតែរំលោភយកដីដែលសហគមន៍ធ្លាប់ប្រើប្រាស់តាមរូបភាពផ្សេងៗក្នុងការចិញ្ចឹមជីវិត ជួនកាលធ្លាប់ប្រើប្រាស់តាំងពីច្រើនជំនាន់ហើយ[៤]។ រដ្ឋាភិបាលបានអះអាងថាសម្បទានដីសេដ្ឋកិច្ចជាមធ្យោបាយសម្រាប់ធ្វើការអភិវឌ្ឍន៍ ប៉ុន្តែជាក់ស្តែង សម្បទានដីសេដ្ឋកិច្ចតែងតែបំផ្លាញជីវភាពរបស់សហគមន៍នៅទីនោះ ហើយការងារដែលបានបង្ករនោះ ភាគច្រើមានតែសម្រាប់អ្នកមកពីក្រៅតំបន់សម្បទាន។ សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាធ្លាប់រងការរិះគន់ដោយអង្គការសិទ្ធិមនុស្ស និង ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិនៅកម្ពុជា[៥]។

នៅឆ្នាំ ២០១២ ដោយបង្ហាញពីការទទួលស្គាល់ថាសម្បទានដីសេដ្ឋកិច្ចមានការប៉ះពាល់ធ្ងន់ធ្ងរលើសហគមន៍ លោកនាយករដ្ឋមន្ត្រីបានប្រកាសឈប់ផ្តល់សម្បទានដីសេដ្ឋកិច្ចបន្ត[៦]។ លោកក៏បានប្រកាសផងដែរអំពីរបៀបកាត់បន្ថយទំហំដីសម្បទានសេដ្ឋកិច្ចដែលហៅថា យុទ្ធសាស្ត្រស្បែកខ្លា ដោយផ្តល់ប័ណ្ណកម្មសិទ្ធិដល់គ្រួសារនីមួយៗលើដីដែលស្ថិតនៅក្នុងដីសម្បទិន និងកាត់ដីខ្លះទៀតទុកសំរាប់គ្រួសារជំនាន់ក្រោយ។ លោកក៏បានបញ្ជាអោយមានការពិនិត្យឡើងវិញនូវរាល់សម្បទានដីសេដ្ឋកិច្ចដែលមានហើយ រួចលុបសម្បទានណាដែលក្នុងនោះមានការរំលោភច្បាប់ ឬកិច្ចសន្យា។ វិធានទាំងអស់នេះត្រូវបានចែងជាផ្លូវការក្នុងបទបញ្ជាលេខ០១ ស្តីពីវិធានពង្រឹង និងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ឬ ហៅកាត់ថា បទបញ្ជា០១។

បញ្ហាបង្ករមកពីសម្បទានដីសេដ្ឋកិច្ចនៅតែមានជាបន្តបន្ទាប់ក្រោយការអនុវត្តន៍បទបញ្ជាលេខ០១[៧] ជាពិសេសក្នុងករណីដីសម្បទានរបស់ក្រុមហ៊ុនទាំង៥ សម្រាប់ដាំអំពៅនៅខេត្តព្រះវិហារ។ ប៉ុន្តែ សហគមន៍ដែលរងផលប៉ះពាល់ដោយដីសម្បទានសេដ្ឋកិច្ចទាំង ៥ នេះនៅតែមានភាពរឹងមាំក្នុងការតស៊ូរបស់ពួកគាត់ចំពោះក្រុមហ៊ុន និងដីសម្បទានរបស់ក្រុមហ៊ុន ដោយប្រឆាំងការបំផ្លាញជីវភាព និង វប្បធម៌របស់ពួកគាត់ ដែលនៅតែបន្តមិនឈប់សោះ។ ពួកគាត់បានតស៊ូបែបនេះក្នុងបរិយាកាសកាន់តែដុនដាបផ្នែកសិទ្ធិមនុស្សនៅកម្ពុជា[៨]។




ផែនទី: ក្រុមហ៊ុនស្ករអំពៅចិនក្នុងខេត្តព្រះវិហារ

## ក្រុមហ៊ុនទាំងប្រាំ និងសម្បទានស្ករអំពៅរបស់ពួកគេ

ផ្អែកលើការស្រាវជ្រាវរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ[៩] នៅឆ្នាំ ២០១៦ ក្រុមហ៊ុនទាំង ៥ គឺ ហេងណុង ហេងរ៉ុយ ឡានហេង ហេងយូ និង រ៉ុយហេង ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនតែមួយ ឈ្មោះហេងហ្វ៊ូគ្រុបស៊ីហ្គែអ៊ីនដាស់ទ្រីHengfu Group Sugar Industry ហៅហេងហ្វ៊ូ ក្នុងភាពជាដៃគូជាមួយក្រុមហ៊ុន ចានចៀងហួដាត្រេឌីងកុំប៉ានីលីមីទីដ Zhanjiang Huada Trading Company Limited ហៅហួដា ដែលក្រុមហ៊ុនទាំងពីរមានទីតាំងនៅខេត្តក្វាងដុង ប្រទេសចិន[១០]។ ក្រុមហ៊ុនទាំង ៥ ដែលមានដីសម្បទាននៅព្រះវិហារនោះ មានស្នាក់ការរួមគ្នាតែមួយនៅរាជធានីភ្នំពេញ ហើយកិច្ចសន្យាដែលគេរកឃើញសម្រាប់ក្រុមហ៊ុន ៣ ត្រូវបានចុះថ្ងៃតែមួយ គឺថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១១។

ដោយប្រទេសចិនគឺជាប្រភពធំជាងគេសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស FDI សម្រាប់ប្រទេសកម្ពុជា ដីសម្បទានទាំងនេះមានសារៈសំខាន់បំផុតសម្រាប់រដ្ឋាភិបាលកម្ពុជា បង្ហាញពីការទំនាក់ទំនងផ្លូវសេដ្ឋកិច្ច និង ផ្លូវទូត រវាងប្រទេសកម្ពុជា និងប្រទេសចិន និងការប្រឹងប្រែងរបស់កម្ពុជាក្នុងការទាក់ទាញក្រុមហ៊ុនចិនធ្វើការវិនិយោគលើវិស័យកសិឧស្សាហកម្មនៅប្រទេសកម្ពុជា[១១]។

អង្គការមិនមែនរដ្ឋាភិបាលដដែលនោះបានរកឃើញថា ភាគច្រើន ស្ថាប័នចិន ទាំងរបស់រដ្ឋ និង ឯកជន ជាម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនហេងហ្វ៊ូក៏ដូចជាក្រុមហ៊ុនហួដា ហើយជាអ្នកផ្តល់ទុនកម្ចីអោយក្រុមហ៊ុនទាំងពីរនេះដែរ។ ប៉ុន្តែ ក្រុមហ៊ុនទាំងពីរក៏បានទទួលប្រាក់កម្ចីពីធនាគារបរទេសដូចជា ប៊ី.អិន.ភី.ប៉ារីបាស របស់បារាំង និង ធនាគារអភិវឌ្ឍន៍កូរ៉េ របស់កូរ៉េខាងត្បូង។ ក្រៅពីនោះ សាជីវកម្មវិស័យធនាគារអនិកជនចិន ហៅកាត់ថា អូ.ស៊ី.ប៊ី.ស៊ី. ជាធនាគារដ៏លេចធ្លោមួយនៅសិង្ហបុរី ធ្លាប់ទទួលរង្វាន់ផ្នែកសហគ្រាសជាច្រើន និងជាសមាជិករបស់ យូ.អិន.គ្លូបាលខំផាក់ មានភាគហ៊ុនក្នុងក្រុមហ៊ុនមួយឈ្មោះ អារិកត្រាស្ត ដែលជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនហួដា។

នៅពេលដំបូង ក្រុមហ៊ុនទាំងនោះបានទទួលសម្បទានលើផ្ទៃដីសរុប៤២,៤២២ ហិកតា ដែលមានទំហំធំជាងទំហំអតិបរមាកំណត់ដោយច្បាប់សម្រាប់ស្ថាប័នតែមួយ គឺតែ ១០,០០០ ហិកតាប៉ុណ្ណោះ។ យុទ្ធសាស្ត្រស្បែកខ្លា ប្រកាសតែមួយខែក្រោយពីក្រុមហ៊ុនទាំងនេះបានចាប់ផ្តើមប្រតិបត្តិការនៅខែមេសា ឆ្នាំ២០១២ ត្រូវបានអនុវត្តក្នុងភូមិជាច្រើនក្នុងតំបន់នេះ ហើយទំហំដីសម្បទានត្រូវបានកាត់បន្ថយ។ តាមការរាយការណ៍របស់អ្នកចូលរួមស្តាប់បទបង្ហាញរបស់អ្នកជំនាញ ក្នុងចំណោមក្រុមហ៊ុនសម្បទានទាំងនេះ ខ្លះត្រូវបានគេពិនិត្យឡើងវិញ ហើយគេបានរកឃើញការខុសឆ្គងយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែ ក្រោយមកមិនមានការកាត់បន្ថយទំហំដីសម្បទាននេះគួរអោយកត់សំគាល់ក៏ដោយ ហើយមិនមានព័ត៌មាន ឬរបាយការណ៍ផ្លូវការពីការពិនិត្យនោះទេ។ ផ្អែកលើឯកសារដែលបានរកឃើញ ផ្ទៃដីសរុប៦,៦៦០ ហិកតាត្រូវបានកាត់ចេញពីផ្ទៃដីដើមរបស់ដីសម្បទានទាំងប្រាំនេះ[១២] ។ ប៉ុន្តែសមាជិកសហគមន៍នៅទីនោះអះអាងថា ផ្ទៃដីដែលកាត់ចេញ ភាគច្រើនបានទៅមន្ត្រី និងអាជ្ញាធរ ដែលធ្វើការជិតស្និទជាមួយក្រុមហ៊ុន។

តាមការរាយការណ៍ ក្រុមហ៊ុនទាំងនេះមានបំណងចង់លក់ស្ករសភាគច្រើនទៅសហគមន៍អឺរ៉ុប ហើយចង់លក់ទៅទីផ្សារនៅឥណ្ឌា និងចិនផងដែរ[១៣]។ រោងចក្រស្ករអំពៅត្រូវបានសម្ពោធនៅខែមេសា ឆ្នាំ២០១៦។ ក្រោយពីការផលិតស្ករសលើកដំបូង រោងចក្របានអសកម្មមួយរយៈ ដែលគេនិយាយថាបណ្ដាលមកពីខ្វះអំពៅ និងមូលហេតុផ្សេងទៀត[១៤]។ រោងចក្របានចាប់ផ្ដើមដំណើរការឡើងវិញតាំងពីខែកុម្ភៈ ឆ្នាំ២០០៧។ នៅពេលអនាគត ក្រៅពីការផលិតស្ករស រោងចក្រនឹងផលិតអេថានុល ជីកំប៉ុសត៍ និង អគ្គីសនីពីជីវម៉ាសផងដែរ[១៥]។

## រសជាតិល្វីងសម្រាប់សហគមន៍នៅខេត្តព្រះវិហារ

រដ្ឋាភិបាលកម្ពុជាបានការពារគោលនយោបាយផ្ដល់សម្បទានដីសេដ្ឋកិច្ចទូទាំងប្រទេស ដោយអះអាងថានឹងបង្កើនការងារធ្វើដល់ប្រជាពលរដ្ឋ និងថវិកាចូលរដ្ឋ។ គោលបំណងពីរនោះហើយដែលជាគោលបំណងដ៏សំខាន់ដែលបានចែងក្នុងអនុក្រិត្យលេខ១៤៦ ស្ដីពីសម្បទានដីសេដ្ឋកិច្ច។ សម្បទានដីសេដ្ឋកិច្ចគឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ធ្វើអោយតំបន់កសិកម្មជាលក្ខណៈគ្រួសារបានកែប្រែជាតំបន់កសិឧស្សាហកម្ម។ ជាក់ស្ដែងការផ្លាស់ប្ដូរនោះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សហគមន៍មូលដ្ឋាន ដោយមិនទាន់ឃើញផ្ដល់ផលប្រយោជន៍អ្វីត្រឡប់មកវិញ[១៦]។

ដូចបានបង្ហាញក្នុងផែនទីខាងលើ ដីសម្បទានស្ករអំពៅទាំង ៥ គ្របដណ្ដប់លើផ្ទៃដីស្ថិតនៅក្នុងឃុំចំនួន ១០ នៅក្នុងស្រុកឆែប ជ័យសែន និងត្បែងមានជ័យ នៃខេត្តព្រះវិហារ[១៧] តែក្រៅពីនោះមានភូមិដទៃរងផលប៉ះពាល់ដែរ។ ការសិក្សាតាមមូលដ្ឋាននៅអំឡុងខែមិនា និងខែមេសា ឆ្នាំ២០១៧ បានអោយដឹងថា ក្រុមហ៊ុនទាំងនេះបានឈូសដីរួចហើយក្នុងភូមិចំនួន ២៥ នៅក្នុងឃុំទាំង ១០។ យោងតាមទិន្នន័យឃុំសង្កាត់ជាផ្លូវការឆ្នាំ២០១២ ចំនួនប្រជាពលរដ្ឋសរុបក្នុងភូមិទាំង ២៥ គឺ ២២,៩៣៤ នៅឆ្នាំនោះ។

មុនពេលបច្ចុប្បន្នមិនសូវយូរប៉ុន្មាន ប្រជាពលរដ្ឋនៅតំបន់ទាំងមូលនេះ និងអ្នកនៅជុំវិញសុទ្ធសឹងតែជាជនជាតិកួយ[១៨] ដែលជាមួយក្នុងចំណោមជនជាតិដើមភាគតិចនៅកម្ពុជាដែលមានពលរដ្ឋច្រើនជាងគេ តែសព្វថ្ងៃប្រជាពលរដ្ឋភាគច្រើនក្នុងភូមិទាំងអស់នេះទទួលស្គាល់ខ្លួនថាជាខ្មែរ ទោះបីមានសារតា ពូជពង្សជាជនជាតិកួយក៏ដោយ ដោយសារមានចំណូលស្រុកច្រើនពីខាងក្រៅ និង ការទទួលយកវប្បធម៌ខ្មែរ។ ប៉ុន្តែប្រជាពលរដ្ឋនៅក្នុងភូមិចំនួន ៧ នៅក្នុងតំបន់ដីសម្បទានស្ករអំពៅ នៅតែទទួលស្គាល់ខ្លួនឯងថាជាជនជាតិដើមភាគតិចកួយ[១៩]។

ច្បាប់នៃប្រទេសកម្ពុជាអនុញ្ញាតអោយសហគមន៍ជនជាតិដើមភាគតិចធ្វើការចុះបញ្ជាដីរបស់ខ្លួនជាលក្ខណៈសមូហភាព តែធ្វើបានតែនៅកំរិតភូមិមួយៗដាច់ដោយឡែក ហើយចំពោះតែប្រភេទដីប្រើប្រាស់ជាក់លាក់ចំនួន ៥ គឺ ៖ ដីកំពុងដាំដុះ ដីលំនៅដ្ឋាន ព្រៃជំនឿ ព្រៃកប់ខ្មោច និង ដីបម្រុងសម្រាប់ពង្រីកកសិកម្មនៅពេលខាងមុខ។ ប័ណ្ណកម្មសិទ្ធិសមូហភាពនោះមិនងាយបានទទួលទេ សព្វថ្ងៃមានសហគមន៍តែ ១៤ ទូទាំងប្រទេសបានទទួលប័ណ្ណរួចហើយ[២០]។ ទោះបីទទួលបានប័ណ្ណហើយក៏ដោយក៏ដីសហគមន៍មិនសូវមានសុវត្ថិភាពដែរ[២១]។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍

៤ ក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចកួយទាំង ៧ បានចាប់ផ្តើមដំណើរការចុះបញ្ជីដីជាសមូហភាព។ ក្នុងនោះ នៅភូមិចំនួន ៣ នៅឃុំប្រមេរ ស្រុកត្បែងមានជ័យ សហគមន៍បានដាក់សំណើដំណើរការចុះបញ្ជីតាំងពីឆ្នាំ២០០៩ មកម្លេះ។ សហគមន៍ទាំង ៣ នោះបានការទទួលស្គាល់ស្វ័យអត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការតាំងពីខែសីហា ឆ្នាំ ២០១២[២២] តែ ៤ ខែក្រោយពីក្រុមហ៊ុនចាប់ផ្តើមដំណើរការឈូសឆាយ។ ពួកគាត់បានសំរេចជំហានទី ២ គឺការទទួលស្គាល់ជានីតិបុគ្គល តាំងពីខែកុម្ភៈ ឆ្នាំ ២០១៤[២៣] តែសព្វថ្ងៃកំពុងរង់ចាំអាជ្ញាធរទទួលស្គាល់ផែនទីបឋមរបស់ដីសមូហភាពរបស់ពួកគាត់[២៤]។ ដូចអាចមើលឃើញក្នុងផែនទីខាងលើ មានការជាន់គ្នាច្រើនរវាងដីដែលសហគមន៍ទាមទារចុះបញ្ជីនិង ដីសម្បទានស្ករអំពៅ។ សហគមន៍ទាំង ៣ នេះបានស្នើសុំវិធានការពារដីសមូហភាពបណ្តោះអាសន្ន សម្រាប់ពេលមិនទាន់បានចុះបញ្ជី តែវិធានការពារនេះ មិនត្រូវបានអនុម័តឡើយរហូតមកទល់ពេលនេះ។

ភាគច្រើននៃភូមិដែលស្ថិតនៅក្នុងតំបន់សម្បទាន ទាំងជនជាតិដើមភាគតិច និងមិនមែនជនជាតិដើមភាគតិច ប្រជាពលរដ្ឋបានបាត់បង់ដីដែលពួកគាត់ធ្លាប់ដាំដុះ ឬដីដែលបានបំរុងទុកដាំដុះនៅពេលអនាគត ថែមទាំងដីប្រើប្រាស់លក្ខណៈផ្សេងៗទៀតផង។ រឿងដែលបានកើតឡើងនៅភូមិជាច្រើនគឺក្រុមហ៊ុនបានឈូសដាំអំពៅព័ទ្ធជុំវិញដីមួយកន្លែង ដោយមិនទុកផ្លូវចេញចូល រួចប្រាប់គ្រួសារម្ចាស់ដីនោះថាគាត់នឹងត្រូវបានផាកពិន័យ ឬឃុំខ្លួន បើសិនភ្លើងឆេះអំពៅ។ ក្រុមហ៊ុនជូនសំណងតិចតួច ហើយគ្រួសារនោះគិតថាខ្លួនមិនមានជម្រើសក្រៅពីបោះបង់ដី និងទទួលសំណងនោះទេ។ ថវិកាដែលគ្រួសារនីមួយៗបានទទួលមានកំរិតទាបបំផុត ជួនកាលតែមួយលានរៀលតែប៉ុណ្ណោះក្នុងមួយហិកតា។ សូម្បីដីដែលមានប័ណ្ណកម្មសិទ្ធិក្រោយការអនុវត្តន៍យុទ្ធសាស្រ្តស្បែកខ្លាក៏ក្រុមហ៊ុនយកដែរ។ នៅភូមិចំនួន ៤ ប្រជាពលរដ្ឋដែលមានប័ណ្ណកម្មសិទ្ធិបានរាយការណ៍ថា ខ្លួនត្រូវបានក្រុមហ៊ុនបង្ខំលក់ដីអោយ ហើយនៅភូមិទាំង ៤ នោះដដែលប្រជាពលរដ្ឋក៏បានរាយការណ៍ថាក្រុមហ៊ុនបានយកដីមានប័ណ្ណខ្លះដោយមិនផ្តល់សំណងអ្វីឡើយ[២៥]។

ទាំងសហគមន៍ជនជាតិដើមភាគតិច និងមិនមែនជាជនជាតិដើមភាគតិច ជីវភាពរបស់ពួកគាត់មិនអាស្រ័យតែលើដីទំហំតូចៗរបស់គ្រួសារមួយៗដែលគេបានចុះបញ្ជីអោយក្រោមយុទ្ធសាស្រ្តស្បែកខ្លា ឬដែលអាជ្ញាធរព្រមទទួលស្គាល់តាំងពីពេលនោះមកទេ។ ប្រជាពលរដ្ឋស្ទើរគ្រប់គ្រួសារប្រកបរបរធ្វើស្រែ ហើយសម្បទានដីសេដ្ឋកិច្ចស្ករអំពៅបានក្តោបយកតំបន់ដែលសំខាន់ៗជាងគេសម្រាប់ការផលិតស្រូវនៅខេត្តព្រះវិហារ[២៦] តែប្រជាពលរដ្ឋក៏អាស្រ័យលើតំបន់ព្រៃឈើសំរាប់ដងជ័រទឹក និង ប្រមូលអនុផលព្រៃឈើដទៃទៀត និងអាស្រ័យលើអូរ ស្ទឹង សំរាប់នេសាទត្រី។ សំខាន់ជាងគេ មានគ្រួសារជាច្រើនទទួលប្រាក់ចំណូលភាគច្រើនរបស់ខ្លួនពីការដងជ័រទឹកពីដើមឈើទាលចាស់ៗដែលដុះតាមព្រៃជាលក្ខណៈធម្មជាតិ។ គ្រួសារភាគច្រើនចិញ្ចឹមគោក្របី ដោយលែងអោយស៊ីស្មៅតាមតំបន់ប្រើប្រាស់រួម[២៧]។ ធន



សហគមន៍បានឃាត់គ្រឿងចក្ររបស់ក្រុមហ៊ុនទុកនៅក្នុងភូមិរបស់ពួកគេ
(រូបថត : សហគមន៍ម្លូព្រៃពីរ)

ធានទាំងអស់នេះកំពុងរងការបំផ្លាញ ដោយព្រៃឈើ អូរ ត្រពាំង ស្រែ និង វាលស្មៅត្រូវបានកែប្រែទៅជាចំការអំពៅ។ ក្រុមហ៊ុនបានកាប់ដើមច្បោះជ័រទឹករាប់ម៉ឺនដើម ដោយផ្តល់សំណងតិចតួចណាស់ ថែមទាំងនិយាយថា បើទទួលសំណងក៏កាប់ មិនទទួលក៏កាប់[២៨]។ នៅពេលត្រពាំង និងអូរបាត់បង់មច្ឆាជាតិដែលប្រជាពលរដ្ឋធ្លាប់អាស្រ័យជាអាហារក៏បានបាត់បង់ដែរ។ តំបន់ជាច្រើនសម្រាប់ឃ្វាលគោក្របីបានបាត់បង់ផងដែរ[២៩]។ នៅស្រុកជ័យសែន ប្រជាពលរដ្ឋក៏បានរាយការណ៍ថា មេការចិនម្នាក់បានបាញ់សម្លាប់ក្របីមួយក្បាលរបស់ប្រជាពលរដ្ឋដើម្បីយកទៅហូប ហើយទីបញ្ចប់បានបង់ប្រាក់ជាសំណង។ នារីម្នាក់ឈ្មោះសុផល រស់នៅភូមិមួយនៅស្រុកឆែបដែលទទួលផលប៉ះពាល់ពីក្រុមហ៊ុន បាននិយាយថា ៖

*"ជីវភាពរបស់ពួកយើងបានទទួលផលប៉ះពាល់ជាខ្លាំងពីការឈូសឆាយព្រៃឈើ យើងមិនអាចប្រមូលផលអនុផលព្រៃឈើបានទៀតទេ។ ពួកខ្ញុំចំណាយពេលច្រើនលើការតាមដានក្រុមហ៊ុនដែលបំផ្លាញស្រូវដែលទើបនឹងដាំ។ ទិន្នផលស្រូវរបស់ពួកខ្ញុំបានថយចុះដោយសារខ្វះដីសម្រាប់ដាំដុះ ហើយតំលៃស្រូវនៅមូលដ្ឋានបានចុះថោកដោយសារក្រុមហ៊ុនក៏ដាំស្រូវបាន និងលក់ក្នុងតំលៃថោក។"*

ប្រជាពលរដ្ឋបានត្អូញត្អែរពីជាតិគីមីដែលក្រុមហ៊ុនប្រើប្រាស់ស្រោចលើដំណាំអំពៅ ហូរចូលក្នុងអូរដែលពួកគាត់អាស្រ័យយកទឹកប្រើប្រាស់[៣០]។ ខែមីនា ឆ្នាំ ២០១៧ ពេលដែលក្រុមហ៊ុនបានចាប់ផ្តើមច្នៃស្ករសឡើងវិញ ត្រីរាប់តោន

បានងាប់ក្នុងស្ទឹងសែន នៅក្រោមចំណុចដែលទឹកហូរមកពីរោងចក្រ។ ប្រជាពលរដ្ឋចោទថាត្រីងាប់បណ្តាលមកពីកាកសំណល់អំពៅកើតចេញពីការប្រតិបត្តិការរបស់រោងចក្រ ដែលហូរចូលក្នុងស្ទឹងសែន[៣១] ។ ពេលដំបូង អាជ្ញាធរមូលដ្ឋាន និងមន្ត្រីបរិស្ថានបានច្រានចោលការលើកឡើងរបស់ប្រជាពលរដ្ឋ តែក្រោយមកពួកគាត់បានទទួលស្គាល់ថាត្រីងាប់ពិតជាបណ្តាលមកពីការប្រតិបត្តិការរបស់ក្រុមហ៊ុន[៣២]។ អូរព្រាល ដែលទទួលកាកសំណលដោយផ្ទាល់ពីរោងចក្រ ហើយដែលហូរចូលស្ទឹងសែន មិនមានមច្ឆាជាតិទៀតឡើយ គឺចាត់ទុកថាជាអូរងាប់ហើយ[៣៣]។

ការប្រតិបត្តការរបស់ក្រុមហ៊ុនទាំងនេះមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសន្តិសុខស្បៀង។ ប្រជាពលរដ្ឋបានបាតបង់កន្លែងរកអាហារពីធម្មជាតិ ហើយការបំផ្លាញបរិស្ថានកំពុងជះឥទ្ធិពលលើប្រព័ន្ធផលិតស្បៀងឆ្ងាយពីតំបន់សម្បទាន។ ការបំពុលត្រីកំពុងប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់សម្បទាន និងរស់នៅក្រោមខ្សែទឹកឆ្ងាយពីសម្បទាន។ ការបាត់បង់តំបន់សំខាន់

## ការរំលោភច្បាប់អន្តរជាតិ និង ច្បាប់នៃប្រទេសកម្ពុជា

រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាចែងថា កម្ពុជានឹង " ទទួលស្គាល់និងគោរព... រាល់សន្ធិសញ្ញា និងកិច្ចសន្យាអន្តរជាតិស្តីពីសិទ្ធិមនុស្ស " ។ ប៉ុន្តែក្រុមហ៊ុនសម្បទានទាំង ៥ សុទ្ធតែមានការរំលោភសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ និង សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ដែលកម្ពុជាជាភាគីហត្ថលេខី។ ប្រជាពលរដ្ឋត្រូវបានគេបណ្តេញចេញពីដីរបស់ខ្លួន ជីវភាព និង វប្បធម៌របស់ពួកគាត់ត្រូវបានបំផ្លាញ ហើយនៅពេលមានការតវ៉ា ពួកគាត់ត្រូវបានប្តឹងឡើងតុលាការ និង ឃុំខ្លួន។

សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ហៅថា យូ.អិ.នឌ្រីប UNDRIP ដែលកម្ពុជាបានចូលរួមអនុម័តក្នុងសមាជរបស់អង្គការសហប្រជាជាតិ ធ្វើការបកស្រាយសិទ្ធិដែលមានចែងក្នុងសន្ធិសញ្ញានានា ចំពោះករណីជនជាតិដើមភាគតិច។ សិទ្ធិសំខាន់មួយដែលចែងក្នុងយូ.អិនឌ្រីបគឺជាសិទ្ធិរបស់ជនជាតិដើមភាគតិចលើដែនដី និង ធនធានរបស់ខ្លួន។ ជាឧទាហរណ៍ មាត្រាទី ១០ ចែងថា " ជនជាតិដើមភាគតិចមិនត្រូវបានបណ្តេញពីដី ឬដែនដីរបស់ខ្លួនដោយការបង្ខំ " ។ ហើយមាត្រាទី ២៦ ចែងថា " ជនជាតិដើមភាគតិចមានសិទ្ធិចំពោះដី ដែនដី និង ធនធានដែលពួកគាត់ធ្លាប់កាន់កាប់ រស់នៅ ឬប្រើប្រាស់ និង ទទួលមកតាមផ្លូវដទៃទៀត ជាប្រពៃណីមក " ។ យូ.អិនឌ្រីបក៏ចែងផងដែរថា ត្រូវមានការយល់ព្រមទុកជាមុនរបស់ជនជាតិដើមភាគតិច ដោយផ្តល់ព័ត៌មានជាមុន និងគ្មានការបង្ខំ ហៅអេហ្វប៊ិក FPIC ដើម្បីអនុវត្តគម្រោងណាមួយ ឬបង្កើតគោលនយោបាយណាមួយ ដែលអាចប៉ះពាល់ដល់ពួកគាត់។ ប៉ុន្តែ សហគមន៍នៅខេត្តព្រះវិហារមិនបានទទួលព័ត៌មានអ្វីពីសម្បទានទាំងអស់នោះមុនគ្រឿងចក្រមកដល់ ហើយដែនដីរបស់សហគមន៍មួយៗត្រូវបានបំផ្លាញ។

ច្បាប់ភូមិបាលឆ្នាំ២០០១ នៃប្រទេសកម្ពុជា អនុញ្ញាតអោយសម្បទានដីសេដ្ឋកិច្ចតែក្រោម១០,០០០ ហិកតាតែប៉ុណ្ណោះសម្រាប់ស្ថាប័នមួយ ហើយក្រុមហ៊ុនទាំង ៥ ច្បាស់ជាត្រូវបានបង្កើតដើម្បីជៀសវាងការកំណត់កំរិតទំហំខាងលើនេះ។ ការចែងក្នុងច្បាប់ភូមិបាលអំពីការការពារសិទ្ធិកាន់កាប់ដីធ្លីរបស់បុគ្គល និង របស់សហគមន៍ក៏មិនត្រូវបានអនុវត្តដែរ។

អនុក្រិត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច អនុម័តតាំងពីឆ្នាំ ២០០៥ ចែងក្នុងមាត្រា ៤ ថា ត្រូវមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន និង សង្គម ថែមទាំងមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរស់នៅមូលដ្ឋាន ជាមុនទើបអាចផ្តល់សម្បទានដីសេដ្ឋកិច្ច មិនអាចមានការជន្លៀសដោយបង្ខំចំពោះអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវគោរពការប្រើប្រាស់ដីរបស់បុគ្គលម្នាក់ៗ។ ការចែងទាំងអស់នេះត្រូវបានរំលោភ។

សម្រាប់ផលិតស្រូវនិងប៉ះពាល់ដល់ការផលិតស្រូវទូទៅក្នុងខេត្ត។ ជាថ្នូរ ក្រុមហ៊ុនបានផលិតស្ករសដើម្បីនាំចេញទៅក្រៅប្រទេស មិនបានចូលរួមចំណែកផលិតស្បៀងសម្រាប់ប្រជាពលរដ្ឋខេត្តព្រះវិហារ ឬប្រជាពលរដ្ឋទូទាំងប្រទេសនោះឡើយ។

ទន្ទឹមនិងផលប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ជាទូទៅ មានប្រជាពលរដ្ឋចំនួនភាគតិចក្នុងឃុំទាំង ១០ បានធ្វើជាកម្មករអោយក្រុមហ៊ុន។ ពិតមែន នៅភូមិចំនួន ៣ មានប្រជាពលរដ្ឋជាច្រើនបានធ្វើកម្មករក្រុមហ៊ុន ដោយខ្លះនិយាយថាគាត់គ្មានជម្រើស តែក្រៅពីនោះមានប្រជាពលរដ្ឋតិចណាស់ក្នុងភូមិនីមួយៗបានធ្វើកម្មករ។ សូម្បីក្នុងភូមិទាំង ៣ នោះ ឱកាសធ្វើការអោយក្រុមហ៊ុនបានថយចុះបើប្រៀបធៀបនឹងពេលមុន។ តម្រូវការកម្មកររបស់ក្រុមហ៊ុនមានច្រើនជាងគេនៅពេលដំបូង ដូចជានៅពេលឈូសដី ដោយឡែកជំហានក្រោយៗត្រូវការកម្មករតិចជាង ដូចជាការប្រមូលផលអំពៅដែលភាគច្រើនធ្វើដោយម៉ាស៊ីន។

ប្រជាពលរដ្ឋនៅភូមិជាច្រើនបាននិយាយថាគាត់មិនចង់ធ្វើការអោយក្រុមហ៊ុនទេ។ ប្រជាពលរដ្ឋខ្លះតាមមូលដ្ឋាននិយាយថាគាត់មិនចេះធ្វើកម្មករ ខ្លះទៀតនិយាយថាគាត់មិនចង់ធ្វើការអោយក្រុមហ៊ុនដោយសារខឹងក្រុមហ៊ុនយកដីគាត់[៣៤]។ ប្រជាពលរដ្ឋនៅភូមិចំនួន៦ ដែលធ្លាប់ធ្វើកម្មករអោយក្រុមហ៊ុននេះបានត្អូញត្អែរថា ក្រុមហ៊ុនមានការយឺតយ៉ាវក្នុងការផ្តល់ថ្លៃឈ្នួលពលកម្មជូនកាលផ្តល់មិនគ្រប់ផង។

តាមការសង្កេត កម្មករដែលស៊ីឈ្នួលក្រុមហ៊ុនស្ករអំពៅនេះ ភាគច្រើនមកពីខេត្តដទៃៗទៀត។ កម្មករមកពីខេត្តដទៃទៀតបាននិយាយថាគាត់បានត្រឡប់ទៅផ្ទះដោយមិនបានទទួលប្រាក់ឈ្នួល[៣៥]។ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ថានភាពមានលក្ខណៈធ្ងន់ធ្ងរហួតដល់មានរបាយការណ៍ថាកម្មករបានចាប់ផ្តើមលក់ប្រេងម៉ាស៊ូតរបស់ក្រុមហ៊ុនដោយសារក្រុមហ៊ុនមិនបានបើកប្រាក់ខែអោយ។ កម្មករយ៉ាងតិច ០២ នាក់ដែលគេចោទបានលក់ប្រេងលួចពីក្រុមហ៊ុន ត្រូវបានអ្នកធ្វើការអោយក្រុមហ៊ុនហេងរ៉ូយវាយដំយ៉ាងខ្លាំង[៣៦]។ មានករណីដទៃទៀតដែលកម្មករត្រូវបានគេវាយធ្វើបាបផងដែរ[៣៧]។ ជាទូទៅ ក្រុមហ៊ុនហាក់ដូចជាមានការរំលោភសិទ្ធិពលកម្មជាលក្ខណៈប្រព័ន្ធដើម្បីកាត់បន្ថយចំណាយលើការប្រតិបត្តិការ។ ជាឧទាហរណ៍ នៅឆ្នាំ ២០១៤ នគរបាលមូលដ្ឋានបានរកឃើញថាក្រុមហ៊ុនឡានហ្វេងបានជួលកម្មករអាយុត្រឹមតែ ១២ ឆ្នាំ[៣៨]។

ព្រៃជំនឿយ៉ាងតិចមួយកន្លែងត្រូវបានបាត់បង់ដោយដំណាំអំពៅជំនួសវិញ[៣៩]។ ក្នុងតំបន់សម្បទានក៏មានយឿនប្រាសាទបូរាណយ៉ាងតិច ១៩ កន្លែង បង្ហាញក្នុងផែនទីខាងលើ ហើយតាមការសង្កេតផ្ទាល់ ក្រុមហ៊ុនក៏បានឈូសដាំអំពៅជុំវិញយឿនប្រាសាទយ៉ាងតិច ១៥ កន្លែង ភាគច្រើនទុកតែ ១ ឬ ២ ហិកតាសំរាប់ប្រាសាទនីមួយៗ។ នៅកន្លែងមួយ មានស្នាមក្រុមហ៊ុនឈូសឆាយយឿនប្រាសាទ ដាំអំពៅម្តងរួចហើយ តែសព្វថ្ងៃប្រាសាទនោះត្រូវបានឆ្មាំអភិរក្សប្រាសាទការពារហើយ[៤០]។

## ប្រជាពលរដ្ឋទាមទារយកវិញអ្វីដែលជារបស់ពួកគាត់

សហគមន៍ដែលរងផលប៉ះពាល់ពីក្រុមហ៊ុនស្ករអំពៅកំពុងតែតតាំងយ៉ាងខ្លាំងជាមួយក្រុមហ៊ុនទាំង ៥ អស់រយៈពេលជាយូរមកហើយ ទោះបីមានភាពខុសៗគ្នាពីភូមិមួយទៅភូមិមួយ។ មិនមានការចងក្រងជាផ្លូវការពិតមែន តែសហគមន៍កំពុងតែសហការគ្នាក្នុងចំណោមឃុំទាំង ១០ កាន់តែច្រើនឡើងៗ[៤១]។ សហគមន៍នីមួយៗមានការទាមទារយៈពេលខ្លី និង ជាក់លាក់ខុសៗគ្នា តែជាទូទៅសហគមន៍ទាំងអស់កំពុងតែទាមទារការលប់ដីសម្បទាន និង ប្រគល់ដីមកអោយពួកគាត់វិញ[៤២]។

សហគមន៍ទាំងអស់នោះបានប្រើវិធីសាស្រ្តជាច្រើនរូបភាពក្នុងការទប់ទល់ជាមួយក្រុមហ៊ុនសម្បទានស្ករអំពៅ។ ភាគច្រើនគាត់បានចាប់ផ្តើមដោយតវ៉ាផ្ទាល់ជាមួយអ្នកបើកបរគ្រឿងចក្រដែលកំពុងឈូសដីរបស់គាត់ ហើយសកម្មភាពនោះបានឈានដល់ការចរចារជាមួយអាជ្ញាធរមូលដ្ឋាន[៤៣]។ ប្រជាពលរដ្ឋក៏បានធ្វើពាក្យបណ្តឹងជាលាយលក្ខអក្សរប្តឹងក្រុមហ៊ុនដល់អាជ្ញាធរខេត្ត និងស្ថាប័នរដ្ឋនៅថ្នាក់ជាតិ តែស្ទើរតែគ្មានលទ្ធផល[៤៤]។ សហគមន៍នៅឃុំប្រមេរ ស្រុកត្បែងមានជ័យបានប្តឹងក្រុមហ៊ុន និងអ្នកបរគ្រឿងចក្រអោយក្រុមហ៊ុនដាក់ទៅតុលាការខេត្តព្រះវិហារ[៤៥] តែតុលាការតម្កល់ទុកមិនចាត់ការ។



ប្រជាពលរដ្ឋទប់ស្កាត់ការឈូសឆាយដីរបស់ពួកគាត់ដោយផ្ទាល់ (រូបថត : សហគមន៍សង្កែពីរ)

ប្រជាពលរដ្ឋក៏បានបញ្ចេញមតិក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកកាសែត សន្និសីទកាសែត ការសម្ភាសន៍តាមវិទ្យុ និង វេទិកាសាធារណៈ[៤៦] តែទោះបីពួកគាត់បានបង្ហាញពីកង្វល់ និង ការទាមទាររបស់ខ្លួន ក៏មិនឃើញមានឥទ្ធិពលអ្វីលើប្រតិបត្តិការរបស់ក្រុមហ៊ុនឡើយ។


កំណត់ហេតុ

នេះជាកំណត់ហេតុប្រជុំដែលបានប្រារព្ធនៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ នៅឃុំប្រមេរ ដែលនៅក្នុងនោះ តំណាងក្រុមហ៊ុន វ៉ុយហ្វេង បានសន្យាថាក្រុមហ៊ុននឹង ផ្អាកឈូសឆាយដីសម្បទានដែលធ្វើអោយពាល់ដល់ដីប្រជាពលរដ្ឋជាដាច់ខាត និង ដោះស្រាយជូនប្រជាពលរដ្ឋអោយបានច្បាស់លាស់ទើបធ្វើការឈូសឆាយបន្តទៀត។

នៅភូមិមួយ ប្រជាពលរដ្ឋបានតវ៉ានៅពេលដំបូង តែក្រោយមកស្ងប់ស្ងាត់ទៅវិញ ដោយបានទទួលសំណងខ្លះៗដែលពួកគាត់យល់ថាត្រូវតែទទួល។ ក្រៅពីនោះ នៅភូមិទាំងអស់ដែលរងផលប៉ះពាល់ផ្ទាល់ពីក្រុមហ៊ុន ការតតាំងជាមួយក្រុមហ៊ុននៅតែមានជាបន្ត តែភូមិខ្លះមានអ្នកចូលរួមតិច ភូមិខ្លះមានអ្នកចូលរួមច្រើន។

ភាគច្រើន ការធ្វើសកម្មភាពផ្ទាល់នៅនឹងកន្លែងដីសម្បទាន គឺជាផ្នែកមួយដ៏សំខាន់ក្នុងយុទ្ធសាស្ត្ររបស់សហគមន៍តាំងពីពេលដំបូង។ ពួកគាត់បានបង្ខំអោយអ្នកបើកបរគ្រឿងចក្រក្រុមហ៊ុនឈប់ឈូសឆាយមួយរយៈ ដោយព័ទ្ធជុំវិញ ហើយមានករណីមួយចំនួន ពួកគាត់បាននាំគ្រឿងចក្រមករក្សាទុកក្នុងភូមិ [៤៧]។ ករណីមួយនៅស្រុកជ័យសែន តាំងពីឆ្នាំ២០១៦ ប្រជាពលរដ្ឋមកពីភូមិចំនួន ៦ បានបិទផ្លូវ បង្ខាំងឡានរបស់ក្រុមហ៊ុនអោយឈប់ដើម្បីចរចារកដំណោះស្រាយ[៤៨]។ ប្រជាពលរដ្ឋនៅស្រុកទាំង ៣ បានបោះជំរុំលើដីរបស់ខ្លួន ដើម្បីបង្ករភាពងាយស្រួលដល់ការឃាមល្បាតការឈូសឆាយរបស់ក្រុមហ៊ុន មានករណីមួយនៅឃុំប្រមេរបានបោះជំរុំរហូតដល់រយៈពេល ៣ ខែ ចាប់ពីខែមករា រហូតដល់ខែមីនា ឆ្នាំ ២០១៤[៤៩]។ មានពីរលើក ប្រជាពលរដ្ឋបានដកអំពៅដែលក្រុមហ៊ុនកំពុងដាំ ចេញពីក្នុងដីស្រែរបស់ពួកគាត់[៥០]។ ប៉ុន្តែ ការធ្វើសកម្មភាពដោយផ្ទាល់បាននាំមកនូវផលលំបាកដល់សហគមន៍ ហើយមានករណីខ្លះប្រជាពលរដ្ឋដែលចូលរួមត្រូវបានប្តឹងឡើងតុលាការខេត្ត[៥១]។

នៅពេលវិធីសាស្ត្រផ្សេងៗមិនបានទទួលលទ្ធផល ប្រជាពលរដ្ឋបានបែរទៅរក អបិយជំនឿអារក្សអ្នកតា។ ពួកគាត់បានធ្វើបុណ្យដាក់បណ្តាសារក្រុមហ៊ុនពីរលើក នៅខែឧសភា ឆ្នាំ ២០១៥[៥២] និង ខែកុម្ភៈ ឆ្នាំ ២០១៧[៥៣]។

ការតវ៉ារបស់សហគមន៍បានទទួលលទ្ធផលខ្លះ ទោះបីដីមួយចំនួនធំរបស់ពួកគាត់ត្រូវបានគ្របដណ្តប់ដោយចំការអំពៅរបស់ក្រុមហ៊ុន ហើយការឈូសឆាយដោយក្រុមហ៊ុននៅតែបន្ត។ ខែមីនា ឆ្នាំ២០១៣ នៅឃុំប្រមេរ ក្រុមហ៊ុនមួយបានសន្យាផ្អាកការឈូសឆាយដីអ្នកភូមិ ពេលមិនទាន់មានដំណោះស្រាយជាមួយសហគមន៍ អាចមើលឃើញឯកសារខាងក្រោមនេះ។ នៅខែមករា ឆ្នាំ ២០១៥ ក្រោយសហគមន៍ប្រមេរបានចាប់គ្រឿងចក្រ ២ គ្រឿង ក្រុមហ៊ុនទាំងពីរបានសន្យាម្តងទៀតផ្អាកការឈូសឆាយ[៥៤]។ ទាំងពីរលើក ក្រុមហ៊ុនមិនបានគោរពសន្យារបស់ខ្លួននោះទេ។

នៅឃុំប្រមេរដដែល តំណាងរាស្ត្រខេត្តព្រះវិហារបានចុះដល់កន្លែងដែលក្រុមហ៊ុនបានឈូសឆាយលើយឿនប្រាសាទបូរាណ និងជីកឃើញវត្ថុបូរាណ ហើយគាត់បានបញ្ជាអោយមន្ត្រីការពារតំបន់នោះដោយបាញ់ថ្នាំក្រហមតាមដើមឈើជាសំគាល់។ ប៉ុន្តែក្រោយមក មិនយូរប៉ុន្មាន ក្រុមហ៊ុនបានចាប់ផ្តើមឈូសកន្លែងហាមឃាត់បន្តទៀត។

សហគមន៍ឃុំសង្កែពីរ ស្រុកឆែប នៅតែរក្សាគោលដៅធំរបស់ពួកគាត់ តែបានទាមទារទុកដី ១,៥៤៩ ហិកតា សម្រាប់បង្កើតព្រៃសហគមន៍។ អាជ្ញាធរបានបង្ហាញពីការយល់ព្រមតាមសំណើរបស់សហគមន៍ តែមិនទាន់មានការសម្រេចចិត្តជាផ្លូវការនោះទេ។ ដីកន្លែងមួយទៀត ដែលប្រជាពលរដ្ឋក្នុងភូមិមួយនៅក្នុងឃុំនេះបានសូមទុក

សម្រាប់សហគមន៍ មានទំហំ៥១ ហិកតា ត្រូវបាន ក្រុមហ៊ុនរំលោភយកដាំអំពៅជិតអស់។

សហគមន៍ឃុំតស៊ូ ស្រុកជ័យសែន បាន និយាយថា ក្រោយពីមានការបិទផ្លូវដូចបាន រៀបរាប់ខាងលើ អាជ្ញាធរបានធ្វើការវាស់វែងដី ទំហំ៦៩៤ ហិកតាសម្រាប់សហគមន៍នៅភូមិមួយ និង ដីទំហំ១,៥៣៥ ហិកតាសម្រាប់សហគមន៍នៅ ភូមិមួយទៀត ប៉ុន្តែ ក្រុមហ៊ុនបានបន្តឈូសកន្លែង ដីទាំងនោះដដែល។ សហគមន៍ នៅភូមិមួយនៅ ឃុំពុទ្រា ក៏ដណ្តឹមបានដីមានទំហំ៨៧ ហិកតា ដែលក្រុមហ៊ុន ហេងណុង បានឈូសរួចហើយ។

នៅខែមេសា ឆ្នាំ ២០១៦ ខណៈពេល សម្ពោធរោងចក្រស្ករអំពៅចិន លោកនាយករដ្ឋមន្ត្រី ប្រហែលជាទទួលស្គាល់ទំនាស់រវាងក្រុមហ៊ុន និងសហគមន៍ បានមានប្រសាសន៍ថា ក្រុមហ៊ុន ទាំងនោះមិនគួរទទួលដីបន្ថែមតាមសំណូមពរ របស់ពួកគេទេ គឺគួរតែទិញអំពៅពីប្រជាពលរដ្ឋ ដែលដាំលើដីខ្លួនឯងទៅវិញ[៥៥]។

## តើអ្វីទៅជាអនាគតរបស់ក្រុមហ៊ុន សម្បទានទាំង ៥ នេះ ?

ថ្មីៗនេះ រដ្ឋាភិបាលចិនបានព្យាយាមគ្រប់គ្រងលើ ផលប៉ះពាល់បរិស្ថាន និង សង្គម របស់ការវិនិយោគក្រៅប្រទេសចិន ជាពិសេសតាំងពីឆ្នាំ២០១៣[៥៦] ក៏ប៉ុន្តែ ការព្យាយាមនោះហាក់ដូចជាមិនមានលទ្ធផលអ្វីគួរអោយកត់សម្គាល់ទេក្នុងករណីនេះ ធ្វើអោយគេមើលឃើញកាន់តែច្បាស់លាស់ថា ដំណោះស្រាយ "ការវិនិយោគលើវិស័យកសិកម្មប្រកបដោយការទទួលខុសត្រូវ" មិនបានបញ្ឈប់ការចាប់រំលោភដីធ្លីឡើយ[៥៧]។ មានតែសហគមន៍នៅខេត្តព្រះវិហារបានជំរុញដោយខ្លួនឯង តាមរយៈញត្តិ សារព័ត៌មាន សកម្មភាពផ្ទាល់នឹងក្រុមហ៊ុន ។ល។ ដើម្បីបន្ថយល្បឿននៃការរំលោភដីធ្លី ហើយនៅទីបញ្ចប់ បញ្ឈប់សម្បទានរបស់ក្រុមហ៊ុន។ សហគមន៍បានទំលាយការពិតអំពីការចាប់រំលោភដីធ្លី ថាវាប្រកបដោយហិង្សា ការបំផ្លិចបំផ្លាញ និងការល្មើសច្បាប់។

ប្រជាពលរដ្ឋនៅភូមិខ្លះដែលរងផលប៉ះពាល់ដោយសម្បទានទាំងអស់នេះ គិតថាក្រុមហ៊ុនកំពុងស្ថិតក្នុងស្ថានភាពទន់ខ្សោយ តែមិនមានការឯកភាពទាំងអស់លើទស្សនៈនេះទេ។ ពួកគាត់លើកឡើងថា បញ្ហាដែលកម្មករជួបក្នុងការបើកប្រាក់ពីក្រុមហ៊ុនកំពុងកើនឡើង ហើយករណីអ្នកធ្វើការអោយក្រុមហ៊ុនវាយកម្មករក៏កំពុងកើនឡើងផងដែរ។ ពួកគាត់និយាយថា អ្នកដែលធ្លាប់ស្ម័គ្រចិត្តលក់ ឬជួលដីអោយក្រុមហ៊ុនមិនទាន់បានទទួលប្រាក់ពីក្រុមហ៊ុន ហើយកំពុងតែដូរចិត្តចំពោះក្រុមហ៊ុន ចង់បានដីរបស់ខ្លួនត្រឡប់មកវិញ។ មានគេធ្លាប់លឺអាជ្ញាធរមូលដ្ឋានដែលធ្វើការអោយក្រុមហុនរអ៊ូថា មិនបានទទួលប្រាក់ពេញលេញសម្រាប់សេវាដែលខ្លួនបានបម្រើការងារអោយ[៥៨]។ ក្រៅពីនោះ ការណ៍ដែលត្រីរាប់តោនបានស្លាប់តាមដងស្ទឹងសែន[៥៩] ដែលជាដៃសំខាន់របស់ទន្លេសាប បេះដូងរបស់ប្រទេស និងដែលមានសារៈសំខាន់បំផុតសម្រាប់ ខេត្តព្រះវិហារ បានធ្វើអោយសាធារណៈជនបានផ្តោតកាន់តែច្រើន ហើយយល់ថាមិនល្អ ចំពោះប្រតិបត្តិការសម្បទានទាំងអស់នេះ។

នៅពេលនេះ ក្រុមហ៊ុនទាំង ៥ មិនទាន់បានឈូសឆាយដីទាំងអស់ក្នុងសម្បទានរបស់ខ្លួន ដែលមានទំហំតូចជាងអ្វីដែលក្រុមហ៊ុនបានទទួលនៅពេលដំបូង ក្រោយពីកាត់អស់ ១៥ ភាគរយ

ហើយហាក់ដូចជាក្រុមហ៊ុនមិនបានឈូសឆាយដីអោយបានខ្លាំងដូចពីមុន។ លទ្ធផលនេះប្រហែលជាមកពីការតតាំងរបស់សហគមន៍ ប្រហែលជាមកពីការភ័យខ្លាចអារក្សអ្នកតាដែលសហគមន៍បានបួងសួង អំពាវនាវតាំងពីខែកុម្ភៈកន្លងទៅ ឬប្រហែលជាមកពីការមើលឃើញការបោះឆ្នោតឃុំសង្កាត់នៅខែមិថុនា ឆ្នាំ២០១៧។

រដូវវស្សា ដែលឆ្នាំមុនៗធ្លាប់មានការផ្អាកការឈូសឆាយ ក៏នឹងធ្វើអោយសហគមន៍ទាំងនេះមានពេលវេលាពិចារណាថាខ្លួននឹងធ្វើអ្វីបន្តទៅមុខទៀត៕

# ឯកសារយោង

---

១ ទិន្នន័យពីអង្គការ អូ.ឌី.ស៊ី. ទាញយកពី https://opendevelopmentcambodia.net/

២ Cheng Sokhorng (2016) Giant sugar mill set to open in Preah Vihear. The Phnom Penh Post, 4 February។ ទាញយកពី http://www. phnompenhpost.com/business/giant-sugar-mill-set-open-preah-vihear.

៣ Vrieze, Paul and Kuch Naren (2012) Carving up Cambodia one concession at a time. Cambodia Daily, 10-11 March ទាញយកពី www.licadho-cambodia.org/land2012/Carving%20Up%20Cambodia.pdf

៤ ចូរមើលជាឧទាហរណ៍ Chan Sophal (2015) Managing Public Lands for Equitable and Sustainable Development in Cambodia. Mekong Economic Research Network, Phnom Penh ទាញយកពី http://mernetwork.org/wp-content/uploads/2015/08/PP-3-Cambodia-final.pdf, CCHR (2013) Cambodia: Land in Conflict: an Overview of the Land Situation. Cambodian Center for Human Rights, Phnom Penh ទាញយកពី http://cchrcambodia.org/admin/media/report/report/english/CCHR%20Report%20%20Cambodia%20Land%20in%20Conflict%20An%20Overview%20of%20the%20Land%20Situation%20ENG.pdf, Economic land concessions have resulted in the displacement of more than 400,000 people since 2003. The Guardian (2013) Cambodia's sugar rush leaves farmers feeling bitter at 'land grab' ទាញយកពី https://www.farmlandgrab.org /post/view/22296.

៥ Special Representative of the Secretary-General for Human Rights in Cambodia (2007) Economic Land Concessions in Cambodia: A Human Rights Perspective. United Nations Cambodia Office of the High Commissioner for Human Rights, Phnom Penh ទាញយកពី http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Economic%20Land%20Concession%20-%20a%20human%20rights%20perspective%202007.pdf, Subedi, Surya P. (2012) A human rights analysis of economic and other land concessions in Cambodia. Document number A/HRC/21/63/Add.1/Rev.1. UN Human Rights Council, Geneva ទាញយកពី http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session21/Pages/ListReports.aspx, LICADHO (2009) Land Grabbing & Poverty in Cambodia: the Myth of Development. LICADHO, Phnom Penh ទាញយកពី www.licadho-cambodia.org/reports.php?perm=134, FIDH (2012) Cambodia: A Mounting Human Rights Crisis. Fédération internationale des ligues des droits de l'homme, Paris ទាញយកពី https://www.fidh.org/IMG/pdf/fidh_briefing_note_-_cambodia_20.09.2012_final-2.pdf, Neef, Andreas (2016)

៦ Di Certo, Bridget and Meas Sokchea (2012) PM institutes land concessions moratorium. The Phnom Penh Post, 8 May. ទាញយកពី http://www.phnompenhpost.com/national/pm-institutes-land-concessions-moratorium.

៧ Grimsditch, Mark and Laura Schoenberger (2015) New Actions and Existing Policies: The Implementation and Impacts of Order 01. The
NGO Forum on Cambodia Land and Livelihoods Program, Phnom Penh. ទាញយកពី https://www.ngoforum.org.kh/index.php/
hot-news/events/292-new-actions-and-existing-policies-the-implementation-and-impacts-of-directive-01.

[៨] Human Rights Watch (2017) Cambodia: events of 2016. Human Rights Watch, New York. ទាញយកពី https://www.hrw.org/ world-report/2017/country-chapters/cambodia; Amnesty International (2017) Amnesty International Report 2016/17: the State of the World's Human Rights. Amnesty International, London. ទាញយកពី https://www.amnesty.org/en/documents/pol10/4800/2017/en/.

[៩] Follow the Money to Justice (2016) Investment Chain Report: Economic Land Concessions in Preah Vihear Province.

[១០] See also May Titthara (2014) Sleeping with one eye open. The Phnom Penh Post, 29 January. ទាញយកពី http://www.phnompenhpost.com/national/sleeping-one-eye-open.

[១១] See, for example, Xinhua (2016) Chinese-invested giant sugar mill starts operations in Cambodia. Xinhua, 19 April. ទាញយកពី http:// news.xinhuanet.com/english/2016-04/20/c_135297056.htm.

[១២] Data from Open Development Cambodia. ទាញយកពី https://opendevelopmentcambodia.net/.

[១៣] Cheng Sokhorng (2016) *Giant sugar mill set to open in Preah Vihear.* The Phnom Penh Post, 4 February. ទាញយកពី http://www.phnompenhpost.com/business/giant-sugar-mill-set-open-preah-vihear.

[១៤] Chheng Sokhorng (2016) Monster sugar mill eats through sugarcane supply. The Phnom Penh Post, 8 August. ទាញយកពី http:// www.phnompenhpost.com/business/monster-sugar-mill-eats-through-sugarcane-supply.

[១៥] Sor Chandara (2016) *Massive sugar mill poised to expand*. The Phnom Penh Post, 20 April. ទាញយកពី http://www.phnompenhpost. com/business/massive-sugar-mill-poised-expand.

[១៦] Scheidel, Arnim (2016) *Tactics of land capture through claims of poverty reduction in Cambodia*. Geoforum 75: 110-114.

[១៧] A commune is the second-lowest administrative unit in Cambodia, above the village. The communes are: S'ang, To Su, and Putrea in Chey Sen district, Chhep I, Chhep II, Sangke I, Sangke II, Mlu Prey I, and Mlu Prey II in Chhep district, and Prame in Tbeng Meanchey district.

[១៨] Levy, Paul (1943) Recherches Prehistoriques Dans La Region De Mlu Prei (Cambodge). Ecole Francaise d'Extreme Orient, Hanoi; Seidenfaden, Erik (1952). The Kui people of Cambodia and Siam, Journal of the Siam Society 39(2): 144–183.

[១៩] Interviews with people from 28 villages in the ten communes, conducted in March and April 2017.

[២០] Ministry of Land Management, Urban Planning and Construction (2017) Report summarising the results of implementation of work in 2016 and setting targets for 2017 of the Ministry of Land Management, Urban Planning and Construction. Document number 001 dar.nor. sar.robar., dated 13 January.

[២១] See, for example, Beban, Alice and Pou Sovachana (2014) Human Security & Land Rights in Cambodia. Cambodian Institute for Cooperation and Peace, Phnom Penh. ទាញយកពី www.cicp.org.kh/userfiles/file/Publications/HSLR-report-Final-3-29-2015.pdf.

[២២] Ministry of Rural Development documents numbers 1231/12 kor.or.chor., 1234/12 kor.or.chor, and 1236/12 kor.or.chor, dated 28 August, 2012.

[២៣] Ministry of the Interior documents numbers 218 sor.chor.nor. and 219 sor.chor.nor. dated 7 February, 2014 and 320 sor.chor.nor. dated 17 February, 2014.

[២៤] Although these communities made detailed preliminary maps in 2015 – maps that represent the communities' own claims, recognised by authorities of neighboring communes – they re-started the mapping process in 2016 following a meeting with provincial authorities. See Preah Vihear provincial administration announcement, dated 4 January 2016.

[២៥] Interviews with residents in all ten communes, in March and April 2017.

[២៦] Data from an official government database available at http://db.ncdd.gov.kh/cdbonline/home/index.castle, which is based on report- ing by village chiefs, show that in 2010, rice yields in seven of the ten communes were at least 30% higher than the provincial average.

[២៧] Interviews conducted in 28 villages in the ten communes, in March and April 2017.

[២៨] Based on ongoing data-collection (since 2014) from community members on resin trees cut within the concession.

[២៩] Interviews with residents in 28 villages in the ten communes, in March and April, 2017.

See also Indigenous Peoples and Forestry Network (2013) Report on Land Conflict in Prame Commune, Tbeng Meanchey District, Preah Vihear Province. CIYA, CLEC, NGO Forum on Cambodia, PKH, and ICSO, Phnom Penh.

[៣០] Interviews with residents in Prame commune, Tbeng Meanchey district from 6-9 March, 2017.

[៣១] Chhorn Phearun (2017) *Sugar plantation in Preah Vihear suspected in mass fish deaths*. The Cambodia Daily, 30 March. ទាញយកពី https://www.cambodiadaily.com/news/sugar-plantation-in-preah-vihear-suspected-in-mass-fish-deaths-127243/.

[៣២] Laurence Stevens and Van Roen (2017) *Official Says Fertilizer Caused Fish Deaths; Probe Continuing*. ទាញយកពី https://www.cambo- diadaily.com/news/official-says-fertilizer-caused-fish-deaths-probe-continuing-128033/

[៣៣] Observation, 6 April 2017.

[៣៤] Interviews with residents from 28 villages in the ten communes, in March and April 2017.

[៣៥] Interviews with former company workers living in Kompong Thom province on 17 February 2017.

[៣៦] Down, Aisha (2017) *Police probe beating of sugarcane workers*. The Cambodia Daily, 24 February. ទាញយកពី https://www.cambo- diadaily.com/news/police-probe-beating-of-sugarcane-workers-125744/.

[៣៧] Phak Seangly (2017) *Man claims beating at hands of Rui Feng staff*. The Phnom Penh Post, 13 March. ទាញយកពី http://www. phnompenhpost.com/national/man-claims-beating-hands-rui-feng-staff.

[៣៨] Phak Seangly (2014) Child labourers found: police. The Phnom Penh Post, 25 March. ទាញយកពី http://www.phnompenhpost.com/ national/child-labourers-found-police.

[៣៩] Interviews with community members in Prame commune, Tbeng Meanchey district, conducted between 6 and 9 March 2017.

[៤០] See also Sen David (2014) Rare statue unearthed by Chinese developer. The Phnom Penh Post, 28 February. ទាញយកពី http://www. phnompenhpost.com/national/rare-statue-unearthed-chinese-developer;
AIPP (2014) Threatened Lands, Threatened Lives: Human Rights Situation of the Indigenous Peoples in Cambodia. Asia Indigenous Peoples Pact, Chiang Mai. ទាញយកពី http://aippnet.org /threatened-lands-threatened-lives/.

[៤១] Interviews with community members in Tbeng Meanchey, Chey Sen, and Chhep districts, conducted March and April 2017.

[៤២] See also Phak Seangly and Pech Sotheary (2015) Kuoy, Phnong air grievances. The Phnom Penh Post, 9 January. ទាញយកពី http:// www.phnompenhpost.com/national/kuoy-phnong-air-grievances;
NGO Forum on Cambodia (2014) Indigenous communities from Preah Vihear call for cancellation of the economic land concession and accel- erating the communal land titles. The NGO Forum on Cambodia. ទាញយកពី https://www.ngoforum.org.kh/index.php/hot-news/ events/200-indigenous-communities-from-preah-vihear-call-for-cancellation-of-the-economic-land-concession-and-accelerating-the- communal-land-titles.

[៤៣] See, for example, Lipes, Joshua (2015) *Cambodian villagers block Chinese developer from clearing grazing land*. Radio Free Asia, 24 June. ទាញយកពី http://www.rfa.org/english/news/cambodia/developer-06242015162632.html.

[៤៤] See, for example, Phak Seangly (2015) *New spat for Preah Vihear company*. The Phnom Penh Post, 12 May. ទាញយកពី http://www. phnompenhpost.com/national/new-spat-preah-vihear-company.

[៤៥] See, for example, Phak Seangly (2014) Kuoy file suit over ‘land grab’. The Phnom Penh Post, 9 May. ទាញយកពី http://www. phnompenhpost.com/national/kuoy-file-suit-over-%E2%80%98land-grab%E2%80%99;
Aun Pheap (2015) Minority families file complaint against Chinese firm. The Cambodia Daily, 7 January. ទាញយកពី https://www.cambo- diadaily.com/archives/minority-families-file-complaint-against-chinese-firm-75530/.

[៤៦] See, for example, Phak Seangly and Pech Sotheary (2015) *Kuoy, Phnong air grievances*. The Phnom Penh Post, 9 January. ទាញយកពី http://www.phnompenhpost.com/national/kuoy-phnong-air-grievances.

[៤៧] See, for example, Phak Seangly and May Titthara (2015) *Preah Vihear villagers win small concession*. The Phnom Penh Post, 2 January. ទាញយកពី http://www.phnompenhpost.com/national/preah-vihear-villagers-win-small-concession.

[៤៨] Phak Seangly (2016) *Road block leads to land grab inspection*. The Phnom Penh Post, 4 March. ទាញយកពី http://www. phnompenhpost.com/national/road-block-leads-land-grab-inspection.

[៤៩] See, for example, May Titthara (2014) Sleeping with one eye open. The Phnom Penh Post, 29 January. ទាញយកពី http://www. phnompenhpost.com/national/sleeping-one-eye-open.

[៥០] One is documented here: Phak Seangly (2014) *Crops pulled: locals and NGO staffer questioned*. The Phnom Penh Post, 31 July. ទាញយកពី http://www.phnompenhpost.com/national/crops-pulled-locals-and-ngo-staffer-questioned.

[៥១] See, for example, May Titthara, Pech Sotheary, and Phak Seangly (2014) Villagers taking Hun Sen at his word. Phnom Penh Post, 26 August. ទាញយកពី http://www.phnompenhpost.com/national/villagers-taking-hun-sen-his-word.

[៥២] Phak Seangly (2015) Tigers, cobras wished on firm. The Phnom Penh Post, 19 May. ទាញយកពី http://www.phnompenhpost.com/national/tigers-cobras-wished-firm.

[៥៣] Phak Seangly (2017) Locals seek spirits' help. The Phnom Penh Post, 24 February. ទាញយកពី http://www.phnompenhpost.com/national/locals-seek-spirits-help.

[៥៤] Phak Seangly and May Titthara (2015) *Preah Vihear villagers win small concession*. The Phnom Penh Post, 2 January. ទាញយកពី http://www.phnompenhpost.com/national/preah-vihear-villagers-win-small-concession.

[៥៥] Khmer Economy Magazine (2016) Chinese investment helps to promote Cambodian economic development: the largest sugar processing factory in Asia, in Preah Vihear, is officially opened. 19 May. ទាញយកពី: http://www.khmereco.com/index.php?menu1=3673145&artid=74211031&lg=kh.

[៥៦] Ministry of Commerce of the People's Republic of China (2013) *Guidelines for Environmental Protection in Foreign Investment and Cooperation*. ទាញយកពី http://english.mofcom.gov.cn/article/policyrelease/bbb/201303/20130300043226.shtml and http://www. wri.org/blog /2013/05/how-are-china%E2%80%99s-overseas-investments-affecting-environment

[៥៧] GRAIN (2015) Socially responsible farmland investment: a growing trap. ទាញយកពី https://www.grain.org /article/entries/5294-socially-responsible-farmland-investment-a-growing-trap

[៥៨] Interview with Chhep resident on 12 April, 2017.

[៥៩] Laurence Stevens and Van Roen (2017) Official Says Fertilizer Caused Fish Deaths; Probe Continuing. ទាញយកពី https://www.cambodiadaily.com/news/official-says-fertilizer-caused-fish-deaths-probe-continuing-128033/

របាយការណ៍នេះ ផលិតដោយ :

បណ្ដាញសហគមន៍ដើម្បីសកម្មភាព (ស៊ី.អិន.អេ) អង្គការពន្លកខ្មែរ (ភី.ខេ.អេក)

អង្គការប្រេហ្គន (GRAIN) សមាគមយុជនជនជាតិដើមភាគតិចកម្ពុជា (ស៊ីយ៉ា)

សម្ព័ន្ធជនជាតិដើមភាគតិចអាស៊ី (អេ.អាយ.ភី.ភី)